**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

## សារលិខិតរំលែកទុក្ខ

### នាយឧត្តមសេនីយ៍ ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ ផ្ញើជូនក្មួយៗ ព្រមទាំងចៅៗ

**ក្មួយៗ និងចៅៗ ជាទីស្រឡាញ់រាប់អានដ៏ជ្រាលជ្រៅ !**

ខ្ញុំមានសេចក្តីតក់ស្លុតរន្ធត់ចិត្តនិងក្តុកក្តួលឥតឧបមា បន្ទាប់ពីទទួលដំណឹងដ៏សែនក្រៀមក្រំចំពោះការទទួលមរណៈភាពរបស់ **សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម** ប្រធានព្រឹទ្ធសភា ប្រធានគណបក្សប្រជាជនកម្ពុជា នាថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០១៥ ត្រូវនឹងថ្ងៃច័ន្ទ ៧ រោច ខែជេស្ឋ ឆ្នាំមមែ សប្តស័ក ពុទ្ធសករាជ ២៥៥៩ វេលាម៉ោង ១៥ និង៤៥ នាទី ក្នុងជន្មាយុ ៨៣ ឆ្នាំ ដោយរោគាពាធ។

ការទទួលមរណៈភាពរបស់ **សម្តេចប្រធាន** គឺជាការបាត់បង់ នូវមគ្គុទ្ទេសក៍ដ៏ឆ្នើមនិងឧត្តុង្គឧត្តមនៃព្រះរាជាណាចក្រកម្ពុជា ដែលក្នុងមួយជីវិតរបស់ **សម្តេច** បានលះបង់កម្លាំងកាយនិងកម្លាំងចិត្តក្នុងការតស៊ូរំដោះជាតិមាតុភូមិឲ្យរួចចាកផុតពីរបបប្រល័យពូជសាសន៍ ប៉ុល ពត និងចូលរួមដឹកនាំ កសាង អភិវឌ្ឍន៍ប្រទេសជាតិឲ្យមានការរីកចម្រើនរុងរឿងដូចបច្ចុប្បន្ននេះ។

ស្ថិតក្នុងឱកាសដ៏ខ្សឹកខ្សួលរំជួលចិត្តនិងស្រណោះអាឡោះអាល័យរកទីបំផុតគ្មាននេះ ខ្ញុំនឹងភរិយាខ្ញុំសូមចូលរួមមរណៈទុក្ខយ៉ាងក្រៀមក្រំបំផុតជាមួយ **ក្មួយៗ ចៅៗ** ព្រមទាំងញាតិការទាំង ៧ សន្តានរបស់ **សម្តេចប្រធាន** និងសូមឧទ្ទិសបួងសួង សូមដួងវិញ្ញាណក្ខន្ធ**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម** បានទៅកាន់សុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។

សូម **ក្មួយៗ និងចៅៗ** ទទួលនូវក្តីស្រឡាញ់ដ៏ជ្រាលជ្រៅបំផុតអំពីខ្ញុំ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១៥

**នាយឧត្តមសេនីយ៍ ទៀ បាញ់**

វិថីហ្សកនីមីត្រូវ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ទូរស័ព្ទ-ទូរសារ៖ ០២៣ ៨៨៣ ២៧៤ អ៊ីមែល៖ generalsec@mod.gov.kh